# ឆ្លងកុដិវត្តធម្មសាមគ្គី

❖ ផែនដីមួយជុំរាងធំជាងគេ　　ផែនទីតូចទេមានឆ្នេរព័ន្ធព័ទ្ធ
មានខ្សែបត់បែនព្រំដែនកំណត់　　គ្រប់គ្រងរាជរដ្ឋប្រាកដប្រជា ។
❖ វាយោចម្លែកប្លែកខុសធម្មតា　　ម្តងក្តៅអស្ចារ្យម្តងថារងា
សមុទ្រព័ទ្ធជុំដីធំមហិមា　　កណ្តាលគង្គាជាប្រទេសមួយ ។
❖ ព្រះពុទ្ធសាសនាមានការផ្សព្វផ្សាយ　　ដល់ជនទាំងឡាយដោះស្រាយទុក្ខព្រួយ
ផ្សាយគ្រប់ទិសទីពីមួយទៅមួយ　　ធម៌ជាជំនួយជួយមករំដោះ ។
❖ សត្វក្នុងលោកាប្រាថ្នាក្តីសុខ　　ភ័យខ្លាចក្តីទុក្ខគ្រប់មុខទាំងអស់
ភ្លេចអំពើល្អបង្កទំនាស់　　ឆ្ងាយសប្បុរសបាត់អស់ខ្លឹមសារ ។
❖ វត្តធម្មសាមគ្គីស៊ីដនីយ៍វត្តខ្មែរ　　កសាងហូរហែថែព្រះសាសនា
ដីអូស្ត្រាលីសាមគ្គីសិក្សា　　ធម៌ព្រះសាស្តាថ្លៃថ្លាកន្លង ។
❖ មានសាលាធំប្រជុំច្រើនជាតិ　　សាងកុដិរួចទៀតបានធ្វើបុណ្យឆ្លង
បីយប់បីថ្ងៃឥតអ្វីសៅហ្មង　　ខ្លឹមសារបុណ្យឆ្លងចម្លងធម្មទាន ។
❖ ដាក់បាត្រព្រះសង្ឃផ្ចិតផ្ចង់ចង្ហាន់　　ប្រគេនលោកឆាន់ចង្ហាន់ដែលមាន
រូបកាយនេះណាមានការស្រេកឃ្លាន　　វេរអាហារទានឆ្ពោះសង្ឃប្រាកដ ។
❖ វេរកុដិថ្វាយសង្ឃផ្ចិតផ្ចង់ស្មារតី　　សេនាសនៈថ្មីលើដីក្នុងវត្ត
កាត់ខ្សែបូផ្តាច់សម្រេចកំណត់　　កុដិសង្ឃប្រាកដជាបុណ្យថ្លៃថ្លា ។
❖ បរិស័ទសប្បាយស្រស់ស្រាយគ្រប់គ្នា　　ព្រមដោយសទ្ធាស្តាប់ធម៌ទេសនា
ព្រះធម៌ខ្ពស់ទាបជ្រាបក្នុងចិន្តា　　បណ្តុះបញ្ញាខ្លឹមសារជីវិត ។
❖ សិក្សាព្រះធម៌លម្អបញ្ញា　　សាងកុដិសាលាថ្វាយសាសនាពិត
ព្រះសង្ឃទ្រង់ធម៌សីលល្អប្រណិត　　បានគង់ស្រួលពិតជ្បិតកុដិសាលា ។
❖ បុណ្យកើនច្រើនជាក់ដល់អ្នកទាំងឡាយ　　ដែលបានខ្វល់ខ្វាយពិធីនេះណា
ចូលរួមទាំងកាយចំណាយថវិកា　　កសាងសេនាសនៈថ្វាយសង្ឃ ។
❖ សូមបុណ្យដែលបានធ្វើពេលនេះណា　　សាងកុដិសាលាអាហារផ្ចិតផ្ចង់
បានវេរប្រគេនចំពោះព្រះសង្ឃ　　ជួយខ្ញុំព្រះអង្គសុខគ្រប់វេលា ។
❖ ខ្ញុំសូមឧទ្ទិសបុណ្យទាំងប៉ុន្មាន　　ជូនញាតិសន្តានឲ្យបានសុខជា
❖ រកស៊ីកើតកើនចម្រើនគ្រប់គ្នា　　សុខគ្រប់វេលារហូតតទៅ ៕

Sydney 21/01/13 ( រៀបរៀងដោយ **អ៊ុំប្រុស** )